**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូន**

**សម្តេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា**

**និងលោកជំទាវ**

***សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់,***

ភរិយាខ្ញុំ និងរូបខ្ញុំ ព្រមទាំងក្រុមគ្រួសារមានសេចក្ដីសោកស្ដាយក្ដុកក្ដួលក្រៀមក្រំបំផុតដោយឧបាសក **គង់ ខាត់** ដែលត្រូវជាបិតាក្មេករបស់សម្តេច និងត្រូវជាបិតាបង្កើតរបស់លោកជំទាវបានទទួលមរណភាពក្នុងជន្មាយុ ១០១ ឈានចូល ១០២ ឆ្នាំ ដោយជរាពាធ ។

មរណភាពរបស់ឧបាសក **គង់ ខាត់** គឺជាការបាត់បង់បិតា ជីតា ប្រកបដោយព្រហ្មវិហារធម៌មួយរូប ដែលបានចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មានកូនចៅប្រកបដោយគន្លងធម៌ ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំនិងរូបខ្ញុំសូមចូលរួមចែករំលែកនូវមរណទុក្ខដោយក្ដីស្រណោះ និងការអាឡោះអាល័យជាមួយសម្តេច លោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្ដីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងអោយដួងវិញ្ញាណក្ខន្ធឧបាសក **គង់ ខាត់** បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសម្តេច និងលោកជំទាវទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*ថ្ងៃ អាទិត្យ ៦ រោច ខែ បុស្ស ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១*

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៨*

**ហ៊ុន សែន**